ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះរាជកំណើតនៃព្រះយេស៊ូ



និពន្ធដោយៈ Edward Hughes

ធ្វើការពន្យល់ដោយៈ M. Maillot
Alastair Paterson

កែសម្រួលដោយៈ E. Frischbutter Sarah S.

បកប្រែដោយៈ www.christian-translation.com

ផលិតដោយៈ Bible for Children
www.M1914.org

©2020 Bible for Children, Inc.
អាជ្ញាប័ណ្ណៈ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

កាលពីយូរលង់ណាស់មកហើយ
ព្រះទ្រង់បានបញ្ជូនទេវតា ហ្គាប់
ព្រីអ៊ែល ទៅជួប នារីក្រមុំជន
ជាតិជូហ្វ៏ទន់ភ្លន់ម្នាក់
ដែលមានឈ្មោះថា ម៉ារី។





គាត់បានប្រាប់នាងថា “នាងនឹងមានកូន ប្រុសម្នាក់ ហើយសូមដាក់ឈ្មោះ គេថា យេស៊ូ។ មនុស្សម្នានឹងហៅ គេថាជាព្រះរាជ បុត្រានៃព្រះដ៏ខ្ពស់បំផុត។ ទ្រង់នឹងសោយរាជ្យជារៀងដរាបតទៅ។”

នារីក្រមុំបានសួរទៅវិញដោយ
ភាពភ្ញាក់ផ្អើលថា “តើរឿងនេះ
កើតបានយ៉ាងដូចម្ដេចទៅ
បើខ្ញុំមិនដែលនៅជាមួយ
បុរសណាម្នាក់ផងនោះ។”



ទេវតាបានប្រាប់ទៅម៉ារីវិញថា
បុត្រានោះ នឹងយាងមកពីព្រះ។
ទ្រង់មិនចាំបាច់
ត្រូវការឪពុកជា
មនុស្សឡើយ។



បន្ទាប់មក ទេវតាក៏បានប្រាប់ទៅម៉ា
រីផងដែរថា អេលីហ្សាប៊ែត ដែលជា
បងប្អូនជីដូនមួយរបស់នាងក៏កំពុង
មានផ្ទៃពោះក្នុងវ័យចំ
ណាស់របស់នាងផ
ងដែរ។ នេះ
ក៏ជាអព្ភូតហេតុ
ដ៏អស្ចា
រ្យមួយដែរ។



មិនយូរប៉ុន្មាន ម៉ារីបានទៅ
លេង អេលីហ្សាប៊ែត។
ពួកគេបានបួងសួង
លើកតម្កើងព្រះ
ជាម្ចាស់ជាមួយគ្នា។



ម៉ារីបានភ្ជាប់ពាក្យទៅ
បុរសម្នាក់ឈ្មោះ ហូសៀ
ប។ ហូសៀប មិន
សប្បាយចិត្តទេពេល
ដែលគាត់បាន
ដឹងថាម៉ារីកំពុង
មានកូន។
គាត់បានគិតថា
ប្រហែលជាឪពុករបស់
កូននេះជាបុរសផ្សេង
ណាម្នាក់ហើយ។



នៅក្នុងការយល់សប្តិ, ទេវតារបស់ព្រះ
បានប្រាប់ហូស្សែបថា កូននេះជាបុត្រ
របស់ព្រះ។ ហូស្សែបត្រូវជួយម៉ារីថែទាំ
ព្រះយេស៊ូ។



ហូសេប្រជឿជាក់ និងគោរពតាមព្រះជាម្ចាស់។ គាត់ក៏ជាអ្នកគោរពតាមច្បាស់របស់ប្រទេសគាត់ផងដែរ។



ដោយសារតែច្បាប់ថ្មី គាត់និងម៉ារីបាន
ចាកចេញទៅភូមិកំណើត
របស់ពួកគាត់
ឈ្មោះ



បិតថ្លេហែម ដើម្បីបង់ពន្ធរបស់ពួកគាត់។

ម៉ារីដល់ពេលសំរាល
កូនរបស់នាងហើយ។



ប៉ុន្តែហូ
ស្យែបមិនអាចរក
បានបន្ទប់ស្នាក់នៅ
ទីណាសោះ។
គ្រប់ផ្ទះសំណាក់
សុទ្ធតែពេញ។



នៅទីបំផុត ហូស្យែបបានរកបានក្រោលសត្វមួយ។ ទីនោះហើយ ដែលជាកន្លែងព្រះឱរសយេស៊ូបានចាប់កំណើត។



មាតាទ្រង់បានដាក់ទ្រង់នៅក្នុង
ស្នូកសត្វមួយដែលជាធម្មតាគឺជា
កន្លែងសម្រាប់ ដាក់ចំណី
សត្វ។



នៅមិនឆ្ងាយពីទីនោះ មានពួកអ្នកគង្វាល
ដែលនៅចាំយាមរក្សាហ្វូង
ចៀមរបស់ពួកគេ។



ទេវតារបស់ព្រះជាម្ចាស់បានលេចឡើង ហើយ
ប្រាប់ពួកគេពីព័ត៌មាន
ដ៏អស្ចារ្យ នេះ។




“នៅថ្ងៃនេះ មានព្រះសង្គ្រោះមួយអង្គបាន
ប្រសូតដល់អ្នករាល់គ្នានៅទីក្រុង
ដេវីដគឺជាព្រះគ្រិស្ទ ជាព្រះអ
ស្ចារ្យ។ ...

... អ្នកនឹងឃើញព្រះឱរសកំពុងផ្ដេក
នៅក្នុងស្នូក សត្វមួយ។”




រំពេចនោះ ទេវតាជាច្រើនបន្ថែមទៀតបាន
លេចឡើងចែងចាំង បានពោល
សរសើរតម្កើងព្រះជាម្ចាស់
ដោយពាក្យថា ...

... “សូមថ្វាយសិរីល្អដល់ព្រះ នៅស្ថានដ៏ខ្ពស់
បំផុត ហើយ សូមអោយសុខសន្តិ
ភាពមាននៅលើផែន
ដីដែលជាទីគាប់ព្រះ
រាជហឫទ័យ
របស់ទ្រង់។”



ពួកអ្នកគង្វាលបានប្រញាប់ទៅក្រោល សត្វ។
ក្រោយពីបានឃើញព្រះឱរសហើយ ពួកគេបាន
ប្រាប់ទៅគ្រប់គ្នាដែលពួកគេបានជួប ពីអ្វី
ដែលទេវតាបាននិយាយអំពីព្រះយេស៊ូ។



៤០ថ្ងៃក្រោយមក ហូស្សែប
និងម៉ារីបាននាំព្រះយេស៊ូទៅ
វិហារនៅ ជេរ៉ូសាឡិម។
មានបុរសម្នាក់ឈ្មោះ
សាយម៉ិន បានលើ
កតម្កើងសរសើរដ
ល់ព្រះជាម្ចាស់សំរាប់
ព្រះឱរស ចំណែក
អាណា ដែលជាស្ត្រីវ័
យចំណាស់ម្នាក់ ...



... និងជាអ្នកបម្រើដល់ព្រះ
ផងនោះក៏បានអរព្រះគុណ
ដល់ព្រះដែលបានប្រ
ទានព្រះបុត្រាទ្រង់
មកស្ថាន
មនុស្សដែរ។



អ្នកទាំងពីរសុទ្ធតែដឹងថា
ព្រះយេស៊ូជាបុត្រារបស់ព្រះ គឺ
ជាព្រះសង្គ្រោះ ដែលបាន
សន្យាថានឹងត្រូវយា
ងមក។ ហូស្សែរបបា
នថ្វាយសត្វស្លាបចំ
នួនពីរដល់ព្រះជា
ម្ចាស់។



នេះគឺជាដង្វាយដែលក្នុង
ក្រឹត្យវិន័យរបស់ព្រះបាន
តម្រូវសំរាប់អ្នកក្រីក្រ
ដែលត្រូវថ្វាយចំពោះ
ព្រះ នៅពេលដែល
ពួកគេយកកូន
ទើបនឹងកើត
បង្ហាញវត្តមាន
ដល់ព្រះជាម្ចាស់។




មួយរយៈពេលក្រោយមក មាន
ផ្កាយពិសេស មួយបាននាំពួក
អ្នក ប្រាជ្ញមកពីប៉ែកខាង
កើតប្រទេសទៅ ជេរ៉ូសាឡិម។


“ពួកលោកបានសួរថា តើបុត្រា
ដែលត្រូវប្រសូតមកធ្វើជាស្ដេច
របស់សាសន៍ជូហ្វនៅទីណា?
ពួកយើងខ្ញុំចង់ថ្វាយបង្គំទ្រង់។”

ស្ដេចហេរ៉ូត បានលីពី
ពួកអ្នកប្រាជ្ញទាំង
នោះ។ ដោយមានព្រះ
ទ័យតក់ស្លុត ទ្រង់ក៏
បានសុំអោយពួកអ្នក
ប្រាជ្ញទាំងនោះប្រាប់
ដល់ទ្រង់វិញផងនៅ
ពេលដែលពួកលោក
រកឃើញព្រះយេស៊ូ។



ទ្រង់បានមានបន្ទូល
កុហកថា “យើងចង់
ថ្វាយបង្គំទ្រង់ដែរ”
តាមពិតទៅ ស្ដេចហេរ៉ូ
ឌចង់សម្លាប់ព្រះយេស៊ូ
ទៅវិញទេ។



ផ្កាយបាននាំពួកអ្នកប្រាជ្ញទៅដល់ចំ
ផ្ទះដែលម៉ារី និងហូស្សែបរស់នៅជាមួយ
ព្រះកុមារយេស៊ូ។



ពួកលោកក៏បានលុតជង្គង់ចុះ
ថ្វាយបង្គំទ្រង់ ព្រមទាំងបានថ្វាយព្រះ
យេស៊ូនូវដង្វាយជា
មាស និងទឹកអប់
ជាច្រើនផងដែរ។



ព្រះជាម្ចាស់បានព្រមាន
ដល់ពួកអ្នកប្រាជ្ញអោយ
ត្រលប់ទៅស្រុករបស់គេ
វិញជាសម្ងាត់។ ស្ដេចហេ
រ៉ូតខឹងសម្បារខ្លាំងណាស់។



ហេតុ តែចង់បំផ្លាញព្រះ
យេស៊ូ ស្តេចដ៏អាក្រក់នេះ
ក៏បានបញ្ជាអោយសំ
លាប់គ្រប់ក្មេងប្រុសៗទាំង
អស់នៅ បិតថ្លេ ហែម។



ប៉ុន្តែស្តេចហេរ៉ូតមិន
អាចបង្កគ្រោះថ្នាក់
ដល់ព្រះបុត្រារបស់
ព្រះបានឡើយ!



ដោយទទួលបានការ
ព្រមានជាមុននៅក្នុង
ការពន្យល់សប្តិ
ហ៊ូស្យែបបាននាំម៉ារី
និងព្រះយេស៊ូគេច
ខ្លួនទៅអេស៊ីប
ដោយសុវត្ថិភាព។





នៅពេលដែលស្តេចហេរ៉ូតសោយទីវង្គត់ ហ្សូសែបបាននាំម៉ារី និងព្រះ

យេស៊ូត្រលប់ពីអេស៊ីបវិញ។ ពួកគេបានរស់នៅក្នុងភូមិតូចមួយឈ្មោះណាសារ៉ែត នៅជិតសមុទ្រកាលីឡេ។

# ព្រះរាជកំណើតនៃព្រះយេស៊ូ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់,
ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ១-២, លូកា ១-២

“ការបើកសម្ដែងនូវព្រះបន្ទូលទ្រង់ផ្ដល់នូវពន្លឺ។” ទំនុកតម្កើង ១១៩៖ ១៣០


ឈប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់
ព្រះអង្គថា៖ ឱព្រះយេស៊ូ ទូលបង្គំជឿហើយថាទ្រង់ជាព្រះ
ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួស
អំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគត
ឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ
ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បី
ទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃ
មួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូម
ជួយទូលបង្គំអោយគោរពទ្រង់ ហើយរស់នៅសំរាប់ទ្រង់
ដូចជាបុត្ររបស់ទ្រង់។ អាមែន។

សូមអានព្រះគម្ពីរ ហើយអធិស្ឋានទៅព្រះជារៀងរាល់ថ្ងៃ!
យ៉ូហាន ៣៖១៦